Joint Climate Change Initiative

JCCI

#១២

ខែសីហា ឆ្នាំ២០១៣

តើមានអ្វីថ្មី | ទំព័រ ១
សេចក្តីសង្ខេបគម្រោងជេ.ស៊ី.ស៊ី.អាយឆ្នាំ២០១២ | ទំព័រ ២
ផែនទីប្រទេសកម្ពុជា | ទំព័រ ៤
សាច់រឿងទទួលបានពីអង្គការដៃគូ | ទំព័រ ៤
កាលបរិច្ឆេទអំពីការប្រែប្រួលអាកាសធាតុសំខាន់ៗ | ទំព័រ ៧

FORUM SYD | CORD | DAN CHURCH AID/CHRISTIAN

សូមទាក់ទងលោក |Johannes Nilsson ជាមន្ត្រីផ្នែកទំនាក់ទំនង
johannes.nilsson@forumsyd.org

## ជូនចំពោះដៃគូគម្រោងអាកាសធាតុទាំងអស់

សូមស្វាគមន៍ចំពោះការចេញផ្សាយព្រឹត្តិបត្រព័ត៌មានចុងក្រោយបង្អស់ អំពី គម្រោងផ្តួចផ្តើមគំនិតរួមស្តីពីការប្រែប្រួលអាកាសធាតុ ដើម្បីចែករំលែកគំនិត បទពិសោធន៍ និង សាច់រឿងពីប្រទេសកម្ពុជា និង ពីទូទាំងតំបន់ទាំងមូល។ យើងខ្ញុំរីករាយក្នុងការទទួលយកនូវការចូលរួមចំណែក មតិយោបល់ និង គំនិតយល់ឃើញទៅលើមាតិកានេះ ហើយយើងបើកទូលាយក្នុងការបោះពុម្ពផ្សាយការចូលរួមរបស់លោកអ្នកដែលមានការពាក់ព័ន្ធ។ សូមអានដោយក្តីរីករាយ !

## តើមានអ្វីថ្មី

### ស៊ី.ស៊ី.ស៊ី.អ៊ិន ៖ ដំណើរឆ្ពោះទៅមុខ

បណ្តាញស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (ស៊ី.ស៊ី.ស៊ី.អ៊ិន) ត្រូវបានបង្កើតឡើងនៅក្នុងខែសីហា ឆ្នាំ២០០៩ ក្នុងគោលបំណងប្រមូលផ្តុំអង្គការសង្គមស៊ីវិល ដើម្បីជំរុញការងារពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។ តួនាទីរបស់ស៊ី.ស៊ី.ស៊ី.អ៊ិន គឺបន្តធ្វើការអភិវឌ្ឍដោយផ្អែកលើសំឡេងដ៏ច្បាស់លាស់របស់សង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា និង របស់ក្រុមសហគមន៍រហូតដល់អង្គការមហាជន អង្គការមិនមែនរដ្ឋាភិបាល និង ការសិក្សាអប់រំ។ នៅក្នុងព្រឹត្តិបត្រព័ត៌មាននេះ ស៊ី.ស៊ី.ស៊ី.អិន មានជំនឿថា ក្រុមអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានមានសារសំខាន់បំផុត ហេតុដូច្នេះហើយទើបផែនការយុទ្ធសាស្ត្រ ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៣ បានឆ្លុះបញ្ចាំងពីតម្រូវការកសាងការឈ្វេងយល់ អំពីបញ្ហាក្នុងមូលដ្ឋានពីសំណាក់អ្នកពាក់ព័ន្ធមកពីខាងក្រៅ។ ផែនការនេះឆ្លុះបញ្ចាំងពីតម្រូវការ ដែលប្រជាជនមូលដ្ឋានត្រូវឈ្វេងយល់អំពីអ្វី ដែលអ្នកខាងក្រៅកំពុងតែនិយាយនៅពេលដែលពួកគាត់ពិភាក្សាអំពី "ការប្រែប្រួលអាកាសធាតុ"។ ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៣ - ២០១៧ ផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើការកសាងសង្គមស៊ីវិល ការកសាងបណ្តាញ និង ការសាងសមត្ថភាពសម្រាប់សមាជិកទាំងឡាយ។ ដំណាក់កាលដំបូងនេះ គាំទ្រផងដែរដល់ការរៀនសូត្រ និង ការចែករំលែកទៅវិញទៅមកតាមរយៈការសិក្សាស្រាវជ្រាវ ការបង្កើតចំណេះដឹង និង ការចែករំលែកព័ត៌មាន។ បន្ទាប់មក ក្នុងនាមជាសង្គមស៊ីវិលមួយ ស៊ី.ស៊ី.ស៊ី.អ៊ិន បង្កើតតួនាទីមួយដែលមានឥទ្ធិពលកាន់តែធំទៅលើការធ្វើគោលនយោបាយ។

**សូមទាក់ទងលោក ស៊្វ សុជាតិ នៅស៊ី.ស៊ី.ស៊ី.អ៊ិន**

### គេហទំព័រគម្រោងជេ.ស៊ី.ស៊ី.អាយ និង បណ្តាញស៊ី.ស៊ី.ស៊ី.អ៊ិន មាននៅលើប្រព័ន្ធអ៊ិនធឺណិតហើយនៅពេលបច្ចុប្បន្ននេះ!

គេហទំព័រគម្រោងជេ.ស៊ី.ស៊ី.អាយ និង បណ្តាញស៊ី.ស៊ី.ស៊ី.អ៊ិន មាននៅលើប្រព័ន្ធអ៊ិនធឺណិតហើយបច្ចុប្បន្ននេះ ដែលមានច្រកពីរតភ្ជាប់គ្នាសម្រាប់អ្នកអនុវត្តការងារអាកាសធាតុនៅក្នុងប្រទេសកម្ពុជាប្រើប្រាស់។

សូមមើលគេហទំព័រ www.jcci-cambodia.org និង www.cccn.org.kh សម្រាប់រៀនសូត្របន្ថែម សម្រាប់បន្ថែមសាច់រឿងរបស់អ្នក និង ផ្តល់មតិយោបល់ទៅលើអត្ថបទផ្សាយ ឬ ទាញយកធនធាននានាពីគេហទំព័រទាំងនេះ។

សូមទាក់ទងលោក Johannes NILSSON ឬ លោក ស៊ូ សុជាតិ

## ការប្រែប្រួលអាកាសធាតុ ៖ បញ្ហាប្រឈមក្នុងការអភិវឌ្ឍ

កំណើនប្រជាជន និង ការអភិវឌ្ឍយ៉ាងឆាប់រហ័សបានជំរុញឱ្យប្រជាជនទៅតាំងទីលំនៅក្នុងតំបន់ដែលមិនត្រូវបានប្រើប្រាស់ទាល់តែសោះពីមុនមក ដោយសារតែភាពងាយកើតមានទឹកជំនន់នៅក្នុងតំបន់ទាំងនោះជាដើម។ រួមជាមួយនឹងភាពតានតឹងបន្ថែមផ្នែកអាកាសធាតុនៅពេលអនាគត វាជាការចង្អុលបង្ហាញយ៉ាងច្បាស់លាស់មួយដែលថា ប្រទេសកម្ពុជានឹងជួបប្រទះស្ថានភាពអាកាសធាតុ ដែលខុសប្លែកពីមុនដ៏គួរឱ្យកត់សម្គាល់នៅក្នុងពេលអនាគត បើប្រៀបធៀបជាមួយនឹងអំឡុងពេលកន្លងទៅថ្មីៗនេះ។

ភាពជោគជ័យក្នុងការទាញប្រជាជនចេញពីភាពក្រីក្រ កំពុងតែដាក់សម្ពាធបន្ថែមទៅលើប្រទេសនេះ ទៅលើអ្នកដឹកនាំ និង ទៅលើប្រជាជនក្នុងការ *ជ្រើសរើស* ផ្លូវអភិវឌ្ឍដែលបញ្ចេញកាបូនទាប ដើម្បីចៀសវាងការប្រព្រឹត្តកំហុសដដែលៗដូចដែលប្រទេសលោក "ខាងលិច" បានធ្វើ។ *បន្តទៅទំព័រទី ៣...*

## ការទាញយកអត្ថបទបោះពុម្ពផ្សាយអំពីគម្រោងជេ.ស៊ី.ស៊ី.អាយ

រួមគ្នាជាមួយនឹងអង្គការខ្លែន អង្គការទស្សនៈពិភពលោក និង អង្គការការីតាសកម្ពុជា គម្រោងជេ.ស៊ី.ស៊ី.អាយបានចងក្រង "សៀវភៅណែនាំអំពីការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដែលជាសៀវភៅណែនាំអំពីការរៀនសូត្រសម្រាប់អង្គការ និង វិទ្យាស្ថានទាំងឡាយនៅក្នុងប្រទេសកម្ពុជា (មានជាភាសាខ្មែរ និង ភាសាអង់គ្លេស) និង "កូនសៀវភៅស្តីពីការអនុវត្តល្អ" (មានជាភាសាអង់គ្លេស និង មានជាភាសាខ្មែរក្នុងពេលឆាប់ៗនេះ) ដោយធ្វើការសម្របសម្រួលការសិក្សារៀនសូត្រ ដែលទទួលបានពីគម្រោងជេ.ស៊ី.ស៊ី.អាយ និង ដៃគូគម្រោងនេះ។ គ្រប់ឯកសារទាំងអស់ គឺមានសម្រាប់ផ្តល់ជូនតបតាមសំណើ ឬ តាមរយៈគេហទំព័រគម្រោងជេ.ស៊ី.ស៊ី.អាយ (www.jcci-cambodia.org)។

សូមទាក់ទងលោក ណុប ប៉ូលីន

## សហគមន៍អនុវត្ត ៖ ការរៀនសូត្រ និង ការចែករំលែកបទពិសោធន៍

លោក លុយ ចាន់សុភា ជាអ្នកសម្របសម្រួលមុខរបរកសិកម្មរបស់អង្គការពន្លឺនៃក្តីសង្ឃឹម (ភី.អ៊ិន.ខេ.អេស) បានចែករំលែកដោយក្តីរីករាយនូវចំណេះដឹងអំពីការគ្រប់គ្រងកសិកម្ម និង បច្ចេកទេសនានាដែលបានប្រើប្រាស់នៅក្នុងភូមិកំណើតរបស់គាត់ទៅដល់សមាជិកដទៃទៀតនៅក្នុងសហគមន៍ ដែលអនុវត្តគម្រោងជេ.ស៊ី.ស៊ី.អាយ ដែលផ្តោតលើកសិកម្ម និង ការគ្រប់គ្រងធនធានធម្មជាតិចុងក្រោយនេះ។ លោកបានមើលឃើញពីគម្លាតរវាងចំណេះដឹង និង ជំនាញអនុវត្តជាក់ស្តែងក្នុងចំណោមបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និង បានយល់ឃើញថា សហគមន៍អនុវត្តគឺជាវេទិកាដ៏ល្អមួយសម្រាប់ដោះស្រាយបញ្ហានេះ។

> "ប្រសិនបើយើងចង់ជួយឱ្យកសិករចាប់ផ្តើមដាំដុះរបស់ពួកគាត់ប្រកបដោយជោគជ័យ យើងត្រូវជួយឱ្យពួកគាត់ចេះវិភាគថ្លៃចំណាយ ពេលវេលា ទីផ្សារ និង តម្លៃ ដូច្នេះពួកគាត់អាចទទួលបានប្រាក់ចំណេញកាន់តែច្រើន។"

នៅក្នុងចំណោមសមាជិកសហគមន៍អនុវត្តចាស់ និង ថ្មីចំនួន ២៧ លោក សុភា គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិកសកម្ម នៅក្នុងសហគមន៍អនុវត្តទី ២ នៅក្នុងខែឧសភា ដែលក្នុងអំឡុងពេលនោះលោក សុភា បានចែករំលែកបទពិសោធន៍ផ្ទាល់របស់លោកទាក់ទងនឹងការដាំត្រសក់ ដោយប្រើប្រព័ន្ធស្រោចស្រពបន្តក់ទឹក និង ការគ្របប្លាស្ទិក ព្រមទាំងគន្លឹះក្នុងការស្វែងរកទីផ្សារ និង ការលក់។ មិនតែប៉ុណ្ណោះ លោក សុភា បានផ្តល់ការបរិយាយលម្អិតច្បាស់លាស់អំពីរបៀបដំណើរការកសិអាជីវកម្ម រួមទាំងការភ្ជាប់ទំនាក់ទំនងទីផ្សារ ការវិភាគច្រវាក់តម្លៃ និង ការវិភាគថ្លៃចំណាយ-ប្រាក់ចំណេញ។ ឧទាហរណ៍ លោកបានផ្តល់ជាឧទាហរណ៍ជាក់ស្តែងមួយតាមរយៈធ្វើការប្រៀបធៀបប្រាក់ចំណូល ដែលរកបានពីការដាំត្រសក់ និង សណ្តែកកួរ ដោយផ្តោតលើការ

ផលិតបានទម្ងន់កាន់តែច្រើន ចំណាយប្រាក់កាន់តែតិច និង ចំណាយពេលវេលាកាន់តែតិច។ លោកសុភាមានប្រសាសន៍ថា "ប្រសិនបើយើងចង់ជួយឱ្យកសិករចាប់ផ្តើមការដាំដុះរបស់ពួកគាត់ប្រកបដោយជោគជ័យ យើងត្រូវតែជួយឱ្យពួកគាត់ចេះវិភាគពីថ្លៃចំណាយ ពេលវេលា ទីផ្សារ និង តម្លៃ ដូច្នេះពួកគាត់អាចទទួលបានប្រាក់ចំណេញកាន់តែច្រើន។ នៅក្នុងពេលជាមួយគ្នានោះដែរ យើងចាំបាច់ត្រូវជួយពួកគាត់ក្នុងការធ្វើផែនការនៅមុនពេលចាប់ផ្តើមការដាំដុះរបស់ពួកគាត់"។

សហគមន៍អនុវត្តន៍ក៏បានរួមបញ្ចូលផងដែរនូវការចុះពិនិត្យដល់តំបន់គោលដៅរបស់អង្គការ អូ.ឌី.អូ.វី នៅក្នុងភូមិអំពិល ក្នុងខេត្តព្រៃវែង ជាកន្លែងដែលលោក សុភា និង អ្នកចូលរួមដទៃទៀតបានរៀនសូត្រពីបច្ចេកទេសកសិកម្មថ្មីៗពីកសិកររបស់គម្រោង។ សិក្ខាសាលារៀនសូត្រនេះ បានប្រមូលផ្តុំកសិករមកពីខេត្តតាកែវ និង កសិករមកពីខេត្តកំពង់ឆ្នាំង ដើម្បីជួបជុំគ្នា ហើយចែករំលែកទៅវិញទៅមកនូវបទពិសោធន៍ និង ការគាំទ្រដល់គ្នាទៅវិញទៅមកលើផ្នែកអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព ព្រមទាំងការប្រើប្រាស់ និង ការគ្រប់គ្រងធនធានធម្មជាតិផងដែរ។ ជាលទ្ធផល សមាជិកសហគមន៍អនុវត្តន៍បានរៀនសូត្រអំពីរបៀប ដែលពួកគាត់អាចជួយគាំទ្រដល់សមាជិកក្នុងសហគមន៍ដទៃទៀតនៅក្នុងតំបន់គោលដៅរបស់ពួកគាត់។ លោក សុភា មានប្រសាសន៍ថា ការរៀនសូត្រអំពីរបៀប ដែលកសិករគំរូរបស់អង្គការសេដាកមកពីខេត្តតាកែវ បានប្រើប្រាស់បំពង់ឫស្សីប្រកបដោយគំនិតច្នៃប្រឌិត ដើម្បីស្តុកទឹកសម្រាប់ស្រោចដំណាំ ដែលនេះជាបច្ចេកទេសដ៏គួរឱ្យចាប់អារម្មណ៍មួយ ព្រោះវាអាចជួយសន្សំទឹក និង ធ្វើឱ្យដំណាំមានសុខភាពល្អនៅក្នុងអំឡុងរដូវប្រាំង។

ក្នុងអំឡុងពេល ២ សប្តាហ៍បន្ទាប់ពីសិក្ខាសាលារៀនសូត្រទី ២ សម្រាប់សហគមន៍អនុវត្តន៍ លោកសុភាបានចែករំលែកនូវអ្វី ដែលលោកបានរៀនសូត្រទៅដល់អ្នករួមការងាររបស់លោក នៅក្នុងអង្គការពន្លឺនៃក្តីសង្ឃឹម ហើយក្រុមការងារនៅក្នុងពេលនេះកំពុងតែរៀបចំអនុវត្តសាកល្បងនូវវិធីសាស្រ្តមួយចំនួនក្នុងចំណោមវិធីសាស្រ្តទាំងឡាយជាមួយនឹងអ្នកទទួលផលគោលដៅរបស់អង្គការពន្លឺនៃក្តីសង្ឃឹម។

### "មធ្យោបាយថ្មីសម្រាប់រៀនសូត្រ និង គាំទ្រដល់គ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព"

លោក សុភា បានសង្ខេបថាសហគមន៍អនុវត្តន៍គឺជា "មធ្យោបាយថ្មីសម្រាប់រៀនសូត្រ និង គាំទ្រដល់គ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព"។ បន្ថែមពីនេះទៅទៀត លោកមានប្រសាសន៍ថា "ខ្ញុំស្រលាញ់សហគមន៍អនុវត្តន៍ ហើយខ្ញុំគិតថា វាជាមធ្យោបាយដ៏ល្អមួយដែលសមាជិកសហគមន៍អនុវត្តន៍ ធ្វើការចែករំលែកការអនុវត្តល្អៗបំផុតដល់គ្នាទៅវិញទៅមក។ ខ្ញុំក៏មានអារម្មណ៍រីករាយផងដែរក្នុងការចែករំលែកបទពិសោធន៍របស់ខ្ញុំទៅដល់អ្នកផ្សេងទៀត"។ ជាមួយនឹងវិធីសាស្រ្តរបស់លោក ក្នុងការគាំទ្រជាបន្តដល់សហគមន៍ទាំងឡាយ សមាជិកសហគមន៍គោលដៅនឹងមានលទ្ធភាពចែករំលែក គាំទ្រ និង រៀនសូត្រពីគ្នាទៅវិញទៅមកដើម្បីបង្កើនជំនាញក្នុងការអភិវឌ្ឍកសិកម្ម និង ការពារធនធាននៅក្នុងសហគមន៍របស់ពួកគាត់ ឈានទៅបង្កើនមុខរបរចិញ្ចឹមជីវិត និង សន្តិសុខស្បៀងរបស់ពួកគាត់។





# ការប្រែប្រួលអាកាសធាតុ៖ បញ្ហាប្រឈមក្នុងការអភិវឌ្ឍ




ការប្រែប្រួលអាកាសធាតុ បានគំរាមកំហែងជាពិសេសដល់ប្រជាជនកម្ពុជា ដែលរស់នៅតាមតំបន់ជនបទឱ្យស្ថិតក្នុងហានិភ័យខ្ពស់នៅក្នុងពេលអនាគត ដោយសារតែសមត្ថភាពបន្សាំមានកម្រិតទាប ឧទាហរណ៍ ភាពក្រីក្រ វិសមភាពសង្គម និង សេដ្ឋកិច្ច លទ្ធភាពប្រើប្រាស់ដីមិនមានសន្តិសុខ និង ធនធានសំខាន់ៗសម្រាប់ការផលិត។ មិនតែប៉ុណ្ណោះ ប្រទេសទាំងមូលក៏ស្ថិតក្នុងហានិភ័យផងដែរជាមួយឥទ្ធិពលសេដ្ឋកិច្ច ដែលបានប៉ាន់ស្មាននៅក្នុងឆ្នាំ២០១០ ថាឈានដល់ ១៥៨៥លានដុល្លារអាមេរិក (៩.៩%នៃផលិតផលក្នុងស្រុកសរុប) និងការប្រមើលមើលសម្រាប់ឆ្នាំ២០៣០ ដែលឡើងដល់ ១៦៧១០លានដុល្លារអាមេរិក (១០.៣%នៃផលិតផលក្នុងស្រុកសរុប) (អង្គការ daraint.org)។

បើទោះបីជាប្រជាជនកម្ពុជាជាច្រើនមិនបានដឹងលម្អិតអំពីពាក្យថា "ការប្រែប្រួលអាកាសធាតុ" ឬ "ការឡើងកម្តៅផែនដី" ក៏ដោយ ក៏មនុស្សភាគច្រើនបានកត់សម្គាល់ពីវា ហើយបានភ្ជាប់បញ្ហានេះទៅនឹងការកាប់បំផ្លាញព្រៃឈើ គ្រោះរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ និង ការកើនជំងឺដង្កាត់ផ្សេងៗ។ ក៏ប៉ុន្តែ អ្វីៗគ្រប់យ៉ាងមិនសុទ្ធតែជាការប្រែប្រួលអាកាសធាតុនោះទេ។ របាយការណ៍មួយចំនួនបានលើកឡើងថា វានៅមិនទាន់មានភស្តុតាងច្បាស់លាស់នៅឡើយទេដែលថា ករណីធ្ងន់ធ្ងរពាក់ព័ន្ធនឹងទឹកជំនន់ និង គ្រោះរាំងស្ងួតដែលបានរាយការណ៍នោះស្ថិតនៅក្រៅវង្វង់នៃបម្រែបម្រួលអាកាសធាតុធម្មតានោះ។ ផ្ទុយទៅវិញ មានការលើកឡើងថា ឥទ្ធិពលដែលបានកើនឡើងនោះ គឺបណ្តាលមកពីឥទ្ធិពលនៃការប្រែប្រួលភូមិសាស្ត្រ និង ការប្រើប្រាស់ដី ក៏ដូចជាការប្រែប្រួលនានាទៅលើទេសភាពបរិស្ថានប្រទេសកម្ពុជាក្នុងអំឡុងពេល ៣-៤ទសវត្សរ៍ចុងក្រោយនេះផងដែរ។ កំណើនប្រជាជន និង ការអភិវឌ្ឍយ៉ាងឆាប់រហ័សបានជំរុញឱ្យប្រជាជនទៅតាំងទីលំនៅក្នុងតំបន់ដែលពីមុនមកមិនត្រូវបានប្រើប្រាស់ទាល់តែសោះ ដោយសារតែភាពងាយរងគ្រោះរបស់តំបន់នោះទៅនឹងទឹកជំនន់ជាដើម។ រួមជាមួយនឹងភាពតានតឹងបន្ថែមនៃអាកាសធាតុនៅក្នុងពេលអនាគត វាជាការចង្អុលបង្ហាញយ៉ាងច្បាស់លាស់មួយថាប្រទេសកម្ពុជានឹងជួបប្រទះស្ថានភាពអាកាសធាតុ ដែលខុសប្លែកពីមុនគួរឱ្យកត់សម្គាល់នៅក្នុងពេលអនាគត បើប្រៀបធៀបជាមួយនឹងអំឡុងពេលដែលបានកន្លងទៅថ្មីៗនេះ (វិទ្យាស្ថានគ្រប់គ្រងទឹកអន្តរជាតិឆ្នាំ២០១០ របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជាឆ្នាំ២០១១ អង្គការសង្គ្រោះសត្វព្រៃកម្ពុជាឆ្នាំ២០១១)។

កម្ពុជាបានក្លាយទៅជាប្រទេសបំភាយកាបូនសុទ្ធសាធនៅក្នុងឆ្នាំ ២០០០ និង ត្រូវបានទស្សទាយថា ព្រៃឈើរបស់ប្រទេសនេះនឹងប្រែក្លាយពីកន្លែងស្តុកទៅជាកន្លែងបំភាយសុទ្ធសាធនៅត្រឹមឆ្នាំ២០៣០។ នៅក្នុងឆ្នាំ ២០០០ ការប្រើប្រាស់ដីមានការប្រែប្រួល ហើយព្រៃឈើ គឺជាអ្នកចូលរួមដ៏ធំបំផុតដែលសរុបជិតស្មើនឹងពាក់កណ្តាលនៃការបំភាយនៅក្នុងឆ្នាំនោះ បើយោងតាមព័ត៌មានបឋមនៅក្នុងអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (យូ.អិន.អែហ្វ.ស៊ី.ស៊ី.ស៊ី) ក្នុងឆ្នាំ២០០២។ ប្រសិនបើសម្លឹងមើលទៅលើការបំភាយនៅថ្នាក់ប្រទេស ប្រទេសកម្ពុជានៅជាអ្នករួមចំណែកតូចមួយនៅឡើយទេ បើទោះបីជាមាននិន្នាការកើនឡើងយ៉ាងគំហុកក៏ដោយ។ តាមរយៈការសម្លឹងមើលកាន់តែច្បាស់ទៅលើនិន្នាការបំភាយក្នុងប្រទេសនីមួយៗក្នុងឆ្នាំ២០១០ ប្រទេសកម្ពុជាបានកើនឡើងលើសពីប្រទេសជិតខាងខ្លួន លើកលែងតែសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និង ប្រទេសប៊្រុយណេ (edgar.jrc.ec.europe.eu) ហើយនៅថ្នាក់ក្រោមជាតិទំនងជាទទួលរងឥទ្ធិពលពីចំនួនយ៉ាងច្រើននៃប្រជាជនដែលរស់នៅតាមសហគមន៍ជនបទ ដែលនៅទីនោះស្ទើរតែគ្មានការបំភាយ។

ចំណុចនេះមានន័យថា ប្រជាជនថ្នាក់កណ្តាល និង ថ្នាក់ខ្ពស់ដែលភាគច្រើនរស់នៅទីក្រុងនោះ បន្សល់នូវស្នាកស្នាមកាន់តែធំគួរឱ្យកត់សម្គាល់ ហើយខិតកាន់តែជិតទៅនឹងមធ្យមភាគជាអន្តរជាតិ។

ជោគជ័យក្នុងការទាញប្រជាជនចេញពីភាពក្រីក្រ កំពុងតែដាក់សម្ពាធបន្ថែមទៅលើប្រទេសនេះ ទៅលើអ្នកដឹកនាំ និង ទៅលើប្រជាជនក្នុង*ការជ្រើសរើស* មធ្យោបាយធ្វើការអភិវឌ្ឍដែលមានផ្លូវបញ្ចេញកាបូនទាបដើម្បីចៀសវាងការប្រព្រឹត្តកំហុសដដែលៗដូចប្រទេសលោក "ខាងលិច" បានធ្វើ។


រូបថត ៖ អង្គការអែហ្វ.អេ.ស៊ី.ធី

## ទិវាដាំព្រៃលិចទឹក

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣ តាមរយៈការធ្វើការរួមគ្នា ដើម្បីថែរក្សាប្រព័ន្ធបរិស្ថានធម្មជាតិឱ្យមានស្ថេរភាព សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (ហ្វេក) បានប្រារព្ធ "ទិវាដាំកូនឈើ" នៅតាមតំបន់ព្រៃលិចទឹកក្នុងឃុំកំពង់ភ្លុក ខេត្តសៀមរាប។ ដោយមានការចូលរួមពីសំណាក់មន្ត្រីថ្នាក់ជាតិ និង ថ្នាក់ខេត្តជាច្រើនរូប ជាពិសេសឯកឧត្តម **ខេម ប៊ុនសុង** ជាទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង ជាអភិបាលខេត្តសៀមរាប អង្គការហ្វេកយល់ឃើញថា ព្រឹត្តិការណ៍នេះ ពិតជាមានឥទ្ធិពលទាំងទៅលើថ្នាក់មូលដ្ឋាន តាមរយៈការលើទឹកចិត្តប្រជាជនមូលដ្ឋានក៏ដូចជាឱ្យជួយគ្រប់គ្រងធនធានធម្មជាតិទាំងនេះ។

# ធនធានសម្រាប់រៀនសូត្រ

## តំបន់សំខាន់ៗ ! ការធ្វើផែនទីបង្ហាញភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅអាស៊ីអាគ្នេយ៍




ការបោះពុម្ពផ្សាយនេះផ្តល់នូវព័ត៌មានអំពីតំបន់ថ្នាក់ក្រោមជាតិ (តំបន់ / ស្រុក / ខេត្ត) ដែលងាយរងគ្រោះបំផុតពីឥទ្ធិពលនៃការប្រែលប្រួលអាកាសធាតុនៅអាស៊ីអាគ្នេយ៍។

ការវាយតម្លៃនេះបានធ្វើឡើងតាមរយៈការផាត់ពណ៌លើផែនទីគ្រោះថ្នាក់ដោយសារអាកាសធាតុ ផែនទីងាយរងគ្រោះថ្នាក់ និង ផែនទីសមត្ថភាពបន្សាំ ដោយអនុលោមទៅតាមក្របខ័ណ្ឌវាយតម្លៃភាពងាយរងគ្រោះរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលរបស់អង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (អាយ.ភី.ស៊ី.ស៊ី)។ ការសិក្សានេះ បានប្រើប្រាស់ទិន្នន័យស្តីពីរបាយគ្រោះថ្នាក់ដោយសារអាកាសធាតុផ្សេងៗគ្នានៅក្នុងតំបន់ថ្នាក់ក្រោមជាតិចំនួន ៥៩០ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ថៃ វៀតណាម ឡាវ កម្ពុជា ម៉ាឡេស៊ី និង ហ្វីលីពីន។ ផ្អែកលើការវាយតម្លៃតាមរយៈការធ្វើផែនទីនេះ គ្រប់តំបន់ទាំងអស់ក្នុងប្រទេសហ្វីលីពីន តំបន់ដីសណ្តទន្លេមេគង្គក្នុងប្រទេសវៀតណាម ស្ទើរតែគ្រប់តំបន់ទាំងអស់ក្នុងប្រទេសកម្ពុជា ភាគខាងជើង និង ភាគខាងកើតប្រទេសឡាវ តំបន់ទីក្រុងបាងកកក្នុងប្រទេសថៃ និង កោះស៊ូម៉ាត្រាភាគខាងលិច កោះស៊ូម៉ាត្រាភាគខាងត្បូង និង កោះជ្វាភាគខាងលិច និង កោះជ្វាភាគខាងកើតក្នុងប្រទេសឥណ្ឌូនេស៊ី ត្រូវបានរកឃើញថា ស្ថិតនៅក្នុងចំណោមតំបន់ដែលងាយទទួលរងគ្រោះបំផុតនៅអាស៊ីអាគ្នេយ៍។

កត្តាជំរុញឱ្យមានភាពងាយរងគ្រោះនេះមានលក្ខណៈផ្សេងៗគ្នានៅទូទាំងប្រទេស និង នៅក្នុងបណ្តាប្រទេសទាំងឡាយ។ ឧទាហរណ៍ កម្រិតដ៏ខ្ពស់នៃភាពងាយរងគ្រោះរបស់តំបន់ទីប្រជុំជនសំខាន់ៗនៅក្នុងប្រទេសឥណ្ឌូនេស៊ី គឺបណ្តាលមកពីដង់ស៊ីតេប្រជាជនដ៏ខ្ពស់នៅក្នុងតំបន់ទាំងនោះ (ភាពប្រឈមនឹងគ្រោះថ្នាក់)។ នៅក្នុងប្រទេសហ្វីលីពីន និង ប្រទេសវៀតណាម ភាពងាយរងគ្រោះ គឺដោយសារតែការប្រឈមយ៉ាងខ្លាំងទៅនឹងគ្រោះថ្នាក់ខ្ពស់ផ្នែកអាកាសធាតុ។ ទោះបីជាបែបណាក្តី នៅក្នុងប្រទេសទាំងនោះ ភាពងាយរងគ្រោះរបស់បណ្តាខេត្តមួយចំនួន គឺពាក់ព័ន្ធច្រើនទៅនឹងសមត្ថភាពបន្សាំរបស់ខេត្តទាំងនោះ។ នៅក្នុងប្រទេសកម្ពុជា និង ប្រទេសឡាវ សមត្ថភាពបន្សាំកម្រិតទាបរបស់ប្រទេសទាំងពីរនេះ គឺជាមូលហេតុចម្បងដែលបណ្តាលឱ្យមានភាពងាយរងគ្រោះកម្រិតខ្ពស់។ អ្វីដែលលទ្ធផលរកឃើញទាំងនេះបានបង្ហាញថា ចាំបាច់ត្រូវធ្វើការកែសម្រួលសកម្មភាពគោលនយោបាយដើម្បីឆ្លើយតបទៅនឹងកត្តាជំរុញជាក់លាក់ក្នុងមូលដ្ឋានដែលបណ្តាលឱ្យមានលក្ខខណ្ឌងាយរងគ្រោះបែបនេះ។

ដើម្បីទាញយកសៀវភៅនេះ សូមមើលគេហទំព័រ កម្មវិធីសេដ្ឋកិច្ច និង បរិស្ថានសម្រាប់តំបន់អាស៊ីអាគ្នេយ៍ (Economy and Environment Program for Southeast Asia's (EEPSA) website.)

## សូមរក្សាទុកកាលបរិច្ឆេទខាងក្រោមនេះ ៖

**សហគមន៍អនុវត្តគម្រោងជេ.ស៊ី.ស៊ី.អាយ** មានគោលដៅលើ ៖

បម្រើជាវេទិកាអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈមួយសម្រាប់អ្នកអនុវត្តការអភិវឌ្ឍ ដែលចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ កម្មវិធីកសិកម្មមាននិរន្តរភាព និង អភិបាលកិច្ចមូលដ្ឋាន ដើម្បីបង្កើនសមត្ថភាពរបស់ពួកគាត់ឱ្យបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពតាមរយៈការចែករំលែកបទពិសោធន៍ទៅវិញទៅមក។

- **អភិបាលកិច្ចក្នុងមូលដ្ឋាន ៖** សហគមន៍អនុវត្តន៍នេះនឹងផ្តោតសំខាន់ទៅលើឧបករណ៍វិភាគ**យេនឌ័រ** ដើម្បីទទួលបានអភិបាលកិច្ចក្នុងមូលដ្ឋានល្អប្រសើរ ស្ថិតក្រោមលក្ខខណ្ឌអាកាសធាតុដែលកំពុងប្រែប្រួល។
  *ទំនាក់ទំនង ៖* ស៊ីម សម្បត្តិ អង្គការខដ

- **ការគ្រប់គ្រងធនធានធម្មជាតិ និង កម្មវិធីកសិកម្មមាននិរន្តរភាព ៖** សហគមន៍អនុវត្តន៍នេះនឹងផ្តោតសំខាន់ទៅលើការចែករំលែកទៅវិញទៅមកនូវចំណេះដឹងបច្ចេកទេស និង បទពិសោធន៍នៅក្នុងវិស័យកសិកម្មមាននិរន្តរភាព ស្ថិតក្រោមលក្ខខណ្ឌអាកាសធាតុដែលកំពុងប្រែប្រួល។
  *ទំនាក់ទំនង* ៖ លោកស្រី ឈឺន ថាវី អង្គការខដ

**ការអនុម័តរបាយការណ៍វាយតម្លៃលើកទី ៥ របស់គណៈកម្មាធិការអាយ.ភី.ស៊ី.ស៊ី**

**ក្រុមការងារទី ១** ទីក្រុងស្តុកខូលម៍ ប្រទេស ស៊ុយអ៊ែត ថ្ងៃទី២៣-២៦ ខែកញ្ញា ឆ្នាំ២០១៣
**ក្រុមការងារទី ២** ទីក្រុងយូកូហាម៉ា ប្រទេសជប៉ុន ថ្ងៃទី២៥-២៩ ខែមីនា ឆ្នាំ២០១៤
**ក្រុមការងារទី ៣** ទីក្រុងប៊ែកឡាំង ប្រទេសអាឡឺម៉ង់ ថ្ងៃទី៧-១១ ខែមេសា ឆ្នាំ២០១៤

**គម្រោងនេះទទួលបានការឧបត្ថម្ភថវិកាពី ៖**
ទស្សនៈ និង មតិយោបល់ទាំងឡាយដែលបានលើកឡើងនៅក្នុងគម្រោងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ប្រទេសស៊ុយអ៊ែតឡើយ។
SWEDEN

***ប្រសិនបើលោកអ្នកចង់ចូលរួមចំណែកនៅក្នុងព្រឹត្តិបត្រព័ត៌មាននៃគម្រោងជេ.ស៊ី.ស៊ី.អាយបន្តបន្ទាប់ទៀត សូមបញ្ជាក់ពីអង្គការរបស់អ្នកពាក់ព័ន្ធនឹងសកម្មភាពការងារផ្នែកការប្រែប្រួលអាកាសធាតុ ឬ ផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍អាកាសធាតុសំខាន់ៗ ដោយផ្ញើមកកាន់ Johannes Nilsson ឲ្យបានមុនថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣។***

Joint Climate Change Initiative
JCCI

សហគមន៍ និង អង្គការក្នុងប្រទេសកម្ពុជាកំពុងរៀនសូត្រ និង ធ្វើការរួមគ្នាដើម្បីកសាងសមត្ថភាព និង ភាពស៊ាំ

*គម្រោងគំនិតផ្តួចផ្តើមរួមអំពីអាកាសធាតុ (ជេ.ស៊ី.ស៊ី.អាយ) ត្រូវបានបង្កើតឡើង និង អនុវត្តដោយអង្គការខដ ជំនួយព្រះបារដាណឺម៉ាក/ជំនួយគ្រឹះបរិស័ទ (ឌី.ស៊ី.អេ/ស៊ី.អេ) និង អង្គការហ្វ័រុមស៊ីដ ចាប់តាំងពីខែមករា ឆ្នាំ២០១០មក ហើយបច្ចុប្បន្ននេះបានឈានដល់ដំណាក់កាលទី ៣ របស់ខ្លួនហើយ។ គោលដៅរួមរបស់គម្រោងជេ.ស៊ី.ស៊ី.អាយ គឺធ្វើការកសាងសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន និង សហគមន៍ទាំងឡាយ ដែលគម្រោងនេះធ្វើការជាមួយ ដើម្បីបង្កើត និង អនុវត្តអន្តរាគមន៍ទៅលើការប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធីការងាររបស់ពួកគេ។*